# បដិមាសង្គ្រាមគុរុក្សេត្រ (មហាភារត) រកឃើញនៅប្រាសាទចិន (កោះកេរ)

សង្គ្រាមគុរុក្សេត្រ សំដៅលើឈុតដ៏សំខាន់មួយនៅក្នុងទេវកថាដ៏ល្បីល្បាញរបស់ឥណ្ឌា គឺរឿង "មហាភារត"។ នៅត្រង់ឈុតនេះ រៀបរាប់អំពីសង្គ្រាមដណ្ដើមអំណាចដ៏ខ្លាំងក្លារវាងព្រះរាជវង្សពីរក្រុមដែលត្រូវជាបងប្អូនជីដូនមួយនឹងគ្នា ពោល គឺក្រុមរាជវង្សកោរវ និងបណ្ឌវ។ ជារឿងដ៏អស្ចារ្យបំផុតនៅក្នុងបរិបទសិល្បៈខ្មែរ ឈុតសង្គ្រាមគុរុក្សេត្រ សិល្បករនៅស.វ.ទី១០ បានឆ្លាក់ចេញជារូបបដិមាធំៗចំនួន៩ បង្ហាញអំពីតួអង្គមួយចំនួននៅក្នុងសាច់រឿងនេះ តម្កល់នូវប្រាង្គច្រកចូលខាងលិចប្រាសាទចិន ដែលជាប្រាសាទមួយសាងឡើងអំពីថ្មបាយក្រៀម នៅតំបន់ប្រាសាទកោះកេរ ស្រុកគូលែន ខេត្តព្រះវិហារ។ តើបដិមាសង្គ្រាមគុរុក្សេត្រនៅប្រាសាទចិន មានលក្ខណៈបែបណាខ្លះ?

លោក Eric Bourdenneau ជាអ្នកស្រាវជ្រាវយ៉ាងល្អិតល្អន់អំពីប្រាសាទចិន និងតំបន់កោះកេរទាំងមូល បានសន្និដ្ឋានថា រូបបដិមាបង្ហាញអំពីសាច់រឿងសង្គ្រាមគុរុក្សេត្រ ដែលសិល្បករបុរាណតម្កល់នៅប្រាសាទចិនមានចំនួន៩ (រូបលេខ១)។ សាច់រឿងជាក់ស្ដែងដែលបានបង្ហាញ គឺរៀបរាប់អំពីការប្រយុទ្ធគ្នាដ៏ស៊ីសាច់ហុតឈាមរវាង "ភីម" ដែលជាតួអង្គម្នាក់ក្នុងចំណោមបងប្អូនបណ្ឌវទាំង៥ ប្រយុទ្ធជាមួយ "ទុយ៉ោធន" ដែលជារៀមច្បងគេក្នុងចំណោមបងប្អូនខាងកោរវ។ នៅប្រាសាទចិនដែលជាទីតាំងដើមរកឃើញបដិមាទាំងនោះ សិល្បករតម្រៀបបដិមាភីម (រូបលេខ២) និងទុយ៉ោធន (រូបលេខ៣) នៅត្រង់ចំណុចកណ្ដាល ក្នុងទិសដៅពីកើតទៅលិច ដោយជើងទាំងពីរញែកចេញពីគ្នាដុចជង្គង់សងខាងក្នុងទម្រង់កាយវិការនៃការប្រយុទ្ធសុទ្ធសាធ។ ចំណែកឯ ផ្នែកខាងជើង សិល្បករតម្រៀបរូបបដិមាបងប្អូនបណ្ឌវចំនួន ៣ នាក់ មាន អជ៌ុន (?) សហទេព និងនាកុល (រូបលេខ៤-៦) នៅក្នុងបំណងជាអ្នកមកជួយគាំទ្រការប្រយុទ្ធរបស់ភីម ដែលត្រូវជាបងប្អូនរបស់ព្រះអង្គម្ចាស់ទាំងបីអង្គ។ នៅផ្នែកខាងត្បូងវិញម្ដង សិល្បករតម្រៀបបដិមាចំនួន៤ តំណាងឱ្យអ្នកចូលរួមទស្សនាចំនួន ៤ តួអង្គ មកចូលរួមទស្សនាការប្រយុទ្ធ ដែលលោក Eric Bourdenneau យល់ថា អាចជាតួអង្គព្រះក្រឹស្ណ ពលរាម និងយុធិស្ថិរ (មេទ័ពរបស់រាជវង្សបណ្ឌវ)។ តួអង្គពលរាម (រូបលេខ៧) គឺជាគ្រូរបស់ភីម និងទុយ៉ោធន ដែលជាតួអង្គប្រយុទ្ធទាំងពីរតែម្ដង ដោយពលរាមមកជួយណែនាំពួកគេអំពីរបៀបប្រើប្រាស់ដំបងក្នុងការប្រយុទ្ធ។ ជាទូទៅ ឈុតត្រង់នេះ គឺជាការប្រយុទ្ធគ្នាចុងក្រោយរបស់គូសត្រូវទាំងពីរក្រុមហើយ។ សាច់រឿងដែលមានរៀបរាប់នៅក្នុងគម្ពីរ Bhagavata Gita បញ្ជាក់ថា ការប្រកួតនេះតួអង្គភីមនៅខាងបណ្ឌវ គឺជាអ្នកឈ្នះ ដោយបានសម្លាប់តួអង្គទុយ៉ោធននៅខាងកោរវ។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ប៉ុន្តែ ជាក់ស្តែងរហូតមកទល់ពេលនេះ មានតែបដិមាចំនួន ៦ ប៉ុណ្ណោះ មកពីប្រាសាទចិន ដែលកំពុងរក្សាទុកនៅសារមន្ទីរជាតិកម្ពុជា។ ចំណែក ឯការតាំងបង្ហាញបច្ចុប្បន្ននៅក្នុងសារមន្ទីរជាតិកម្ពុជា អ្នកជំនាញបានតម្រៀបផ្គុំគ្នារូបបដិមាទាំងនោះ ចំនួន ៥ សិនប៉ុណ្ណោះ (រូបលេខ២៨)។ រូបដែលតម្រៀបតាំងបង្ហាញនោះ មានតួអង្គភីម និងទុយ៉ោធន ជាអ្នកប្រយុទ្ធនៅចំកណ្តាល, តួអង្គបងប្អូនរាជវង្សបណ្ឌវចំនួនពីរអង្គ (អជ៊ុន និងសហទេព) ហើយតួអង្គអ្នកទស្សនាមានតែមួយអង្គប៉ុណ្ណោះ គឺពលរាម។ បដិមាទាំងអស់ សុទ្ធសឹងមានទំហំធំប៉ុនទំហំខ្លួនមនុស្ស ជាលក្ខណៈទូទៅរបស់សិល្បៈខ្មែរក្នុងរចនាបថកោះកេរ នៅស.វ.ទី១០។ អ្វីដែលគួរកត់សម្គាល់នោះដែរ លោកសាស្ត្រាចារ្យ Etsuo Uchida អ្នកស្រាវជ្រាវប្រចាំគម្រោងសាកលវិទ្យាល័យវ៉ាសេដា ប្រទេសជប៉ុនសន្និដ្ឋានថា ថ្មភក់ដែលគេយកមកឆ្លាក់ជារូបបដិមានៅប្រាសាទចិន តំបន់កោះកេរ ពុំមែនជាប្រភេទថ្មយកចេញពីតំបន់ភ្នំគូលែន ដូចស្ថាបត្យកម្មនិងចម្លាក់នៅតំបន់អង្គរទេ តែលោកគិតថាអាចជាថ្មដែលគេយកចេញមកពីតំបន់ក្បែរកោះកេរតែម្តង។

សូមបញ្ជាក់ថា ក្នុងចំណោមបដិមាទាំង ៦ ដែលកំពុងស្ថិតនៅសារមន្ទីរជាតិកម្ពុជានៅពេលនេះ មានតែបដិមាចំនួន១ ប៉ុណ្ណោះ ដែលពីមុនមករក្សាទុកនៅឃ្លាំងអភិរក្សដ្ឋានអង្គរ ខេត្តសៀមរាប គឺបដិមាតំណាងតួអង្គអជ៊ុន ដែលសព្វថ្ងៃបាត់បង់ព្រះសិរទៅហើយ។ រីឯបដិមាចំនួន ៥ ផ្សេងទៀត សុទ្ធតែត្រូវបានទទួលបានមកវិញពីបរទេសទាំងអស់ ដ្បិតនៅក្នុងទសវត្សរ៍១៩៧០ បដិមាទាំងនេះ គេបានលួចចេញរត់ពន្ធទៅលក់នៅប្រទេសថៃ និងបន្តលក់ចេញទៅកាន់ទីផ្សារអន្តរជាតិ។ ក្នុងនោះ រូបបដិមាតំណាងតួអង្គសហទេព និងនាកុល ដែលជាបងប្អូនរាជវង្សបណ្ឌវ បានលក់ចេញទៅទីផ្សារសហរដ្ឋអាមេរិច និងប្រមូលទុកដោយសារមន្ទីរ Metropolitan។ រូបបដិមាទាំងពីរនេះ បានប្រគល់ជូនកម្ពុជាវិញនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣ ក្នុងឱកាសដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះក្នុងសម័យប្រជុំប្រចាំឆ្នាំលើកទី៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដែលមានតំណាងមកពីប្រទេសចំនួន២១ ដែលទទួលខុសត្រូវក្នុងការអនុវត្តអនុសញ្ញាបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ ហើយពេលនោះបានប្រគល់ជូនដោយលោក Emily K. Rafferty ប្រធានសារមន្ទីរ Metropolitan នៃសហរដ្ឋអាមេរិច និងទទួលដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ចំណែករូបអ្នកចម្បាំងទុយ៉ោធន បានប្រគល់ជូនកម្ពុជានៅខែធ្នូ ឆ្នាំ២០១៣ ដែលដំបូងឡើយបដិមានេះកាន់កាប់ដោយ Sotheby's។ បន្ទាប់មកទៀត នៅក្នុងខែមិថុនា ឆ្នាំ២០១៨ រូបបដិមាអ្នកចម្បាំងភីម ដែលកាន់កាប់ដោយសារមន្ទីរ Norton Simon នៅសហរដ្ឋអាមេរិច និងបដិមាពលរាម ដែលធ្លាប់ប្រកាសដាក់លក់ដោយលោក Christie

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

កាលពីឆ្នាំ២០០៩ ក៏បានប្រគល់ជូនកម្ពុជាដូចគ្នា ដែលពេលនោះមានការទទួលក្រោមវត្តមានសម្តេច សុខ អាន នៅទីស្តីការគណៈរដ្ឋមន្ត្រី។

ជារួមមក បដិមាបង្ហាញអំពីឈុតឆាកប្រយុទ្ធសង្គ្រាមគុរុក្សេត្រ នៅក្នុងរឿងមហាភារត ដែលរកឃើញនៅប្រាសាទចិន បានបង្ហាញឱ្យឃើញអំពីភាពច្នៃប្រឌិតរបស់សិល្បករខ្មែរនៅស.វ. ទី១០ ដែលបង្កើតជាទស្សនីយភាពថ្មីប្លែកពីសម័យកាលមុនៗទៀតដែលពុំធ្លាប់មានការយករឿងទេវកថាមកឆ្លាក់ចេញជាបដិមាសាស្ត្រឡើយ។ ម្យ៉ាងវិញទៀត បដិមាទាំងនេះ ក៏ជាលើកដំបូងដែរដែលខ្មែរបង្ហាញអំពីសង្គ្រាមគុរុក្សេត្រនៅក្នុងសិល្បៈ។ ប៉ុន្តែ នៅសម័យក្រោយៗទៀត ឈុតនេះគេបានយកមកឆ្លាក់ច្រើននៅតាមជញ្ជាំងប្រាសាទ ឬតាមហោជាង ឧទាហរណ៍ ហោជាងប្រាសាទបន្ទាយស្រី ដែលកំពុងដាក់តាំងបង្ហាញនៅសារមន្ទីរជាតិកម្ពុជា ក្បែររូបបដិមាទាំងនេះស្រាប់ (រូបលេខ៩)៕

## ឯកសារយោង


**Baptiste, P. & Zéphir, T.**

2008. *L'Art Khmer dans les collections du musée Guimet,* Paris.

**Bourdonneau, E.**

2011, *Nouvelles recherches sur Koh Ker (Chok Gargyar): Jayavarman IV et la maitrise des mondes,* Monuments et mémoires de la Fondation Eugene Piot, Vol. 90, no. 1, pp. 95-141.

2011, 'Un trésor du partrimoine cambodgien en vente a Sotheby's: la statue monumentale du 'Duryodhana bondissant' au Pavillon d'entrée II oust du Prasat Chen de Koh Ker" (March 20th, 2011). Report for UNESCO.

2012, "The Duel between Bhima and Duryodhana and the Sculpted Group of the Western Gopura I of Prasat Chen at Koh Ker" (Summer 2012, in collaboration with Phin Samnang/APSARA). Report for UNESCO.

2014, 'Sculped Groups of the Eastern Gopura I in Prasat Chen (Koh Ker, Cambodia) and Khmer Art Collections of American Museum: *The Duel between Valin and Sugriva & The Fight between Narasimha and Hiranyakasipu.* A preliminary report" (September 2014, in collaboration with EFEO and APSARA).

**Ibbitson, J.H.**

2006, *Masterpieces of the National Museum of Cambodia: An Introduction to the Collection,* Norfolk, CT: Friends of Khmer Culture, republished 2012.

**Hauser-Schaublin, B. and Lyndel V.P. (eds)**

2016, *Cultural Property and Contested Ownership: The Trafficking of Artefacts and the Quest for Restitution,* London: Routledge.

**Swart, P.**

2018, Celebrating Khmer Cultural Heritage: Archaeology, Research and Restitution to Cambodia,

**Uchida, E. Kojiro, T. and Ichita, S.**

2014, 'Construction sequence of the Koh Ker monuments in Cambodia deduced from the chemical composition and magnetic susceptibility of its laterites', *Heritage Science.*


អត្ថបទដោយ៖ ម៉ង់ វ៉ាលី




រូបលេខ១៖ រូបភាព 3D បង្ហាញទិដ្ឋភាពដើមនៃបដិមានៅប្រាសាទចិន ដែលសាកល្បងដោយលោក Eric Bourdenneau (ប្រភព៖ French School of Asian Studies EFEO, GrezProd/Cunin)



រូបលេខ២៖ បដិមាអ្នកចម្បាំងភីម ប្រាសាទចិន



រូបលេខ៣៖ បដិមាអ្នកចម្បាំងទុយ៉ោធន ប្រាសាទចិន

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៤៖ បដិមាអជ៌ុន ប្រាសាទចិន



រូបលេខ២៥៖ បដិមាសហទេព ប្រាសាទចិន



រូបលេខ២៦៖ បដិមានាកុល ប្រាសាទចិន



រូបលេខ២៧៖ បដិមាពលរាម ប្រាសាទចិន

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៨៖ បដិមាចំនួន ៩ បង្ហាញអំពីឈុតសង្គ្រាមគុរុក្សេត្រនៃរឿងមហាភារតមកពីប្រាសាទចិន ដាក់តាំងបង្ហាញផ្តុំគ្នានៅសារមន្ទីរជាតិកម្ពុជា*



*រូបលេខ៩៖ ចម្លាក់ហោជាងបង្ហាញអំពីឈុតសង្គ្រាមគុរុក្សេត្រនៃរឿងមហាភារតមកពីប្រាសាទបន្ទាយស្រី ស.វ.ទី១០*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*